**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

TONLE SAP AUTHORITY
**អាជ្ញាធរទន្លេសាប**

លេខ :....០២៨......អទស

**សូមគោរពជូន**
**ឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប**

**កម្មវត្ថុ** ៖ របាយការណ៍លទ្ធផល កិច្ចប្រជុំពិភាក្សាសមាសភាពអាជ្ញាធរទន្លេសាប ស្តីពី ការពង្រឹងយន្តការ ថែរក្សា ការពារ និង គ្រប់គ្រងធនធានធម្មជាតិ និងដែនព្រៃលិចទឹកក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប ។

**យោង** ៖ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ២៤៣ សសរ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២៣ ស្តីពីការកែសម្រួល សមាសភាពរបស់អាជ្ញាធរទន្លេសាប ។

**ជូនភ្ជាប់**៖ បញ្ជីវត្តមានកិច្ចប្រជុំ និងឯកសារផ្សេងៗ ។

ន័យដូចមានចែងក្នុងកម្មវត្ថុ យោង និងឯកសារជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ អាជ្ញាធរទន្លេសាបបានរៀបចំកិច្ចប្រជុំ **"ពិគ្រោះសមាសភាពអាជ្ញាធរទន្លេសាប ស្តីពីពង្រឹងយន្តការថែរក្សា ការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងដែនព្រៃលិចទឹកក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប"** នាថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២៤ នៅសាលប្រជុំទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ដើម្បីប្រមូលផ្តុំចូល ការគាំទ្រ និងការចូលរួមចំណែកពីសមាជិក សមាសភាពរបស់អាជ្ញាធរទន្លេសាប ក្នុងការផ្តល់គំនិតយោបល់ និងការចែករំលែកនូវបទពិសោធន៍ការងារ ដើម្បីធ្វើឱ្យប្រសើរ ឡើងនូវដំណើរការការងារស្ថាប័ន និងពង្រឹងយន្តការថែរក្សា ការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងដែនព្រៃលិចទឹកក្នុងខេត្ត ទាំង៦ ជុំវិញបឹងទន្លេសាប ដែលកិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួង ធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការអាជ្ញាធរ ទន្លេសាប សមាជិកសមាសភាពរបស់អាជ្ញាធរទន្លេសាប តំណាងមកពីក្រសួង ស្ថាប័ន អាជ្ញាធរខេត្តទាំង៨ និងមន្ទីរធនធាន ទឹក និងឧតុនិយមខេត្តទាំង៨ ជុំវិញតំបន់ទន្លេសាបសរុបចំនួន ៥៧ នាក់ (ដូចមានបញ្ជីវត្តមានជូនភ្ជាប់)។

**កិច្ចប្រជុំពិគ្រោះយោបល់ខាងលើ គឺមានគោលបំណងដើម្បី ៖**

1. ស្វែងយល់ពីចេតនាសម្ព័ន្ធការគ្រប់គ្រង ដឹកនាំ និងដំណើរការការងាររបស់អាជ្ញាធរទន្លេសាប
2. កសាងយន្តការការងារ និងផែនការការងារ ក្នុងការពង្រឹងប្រសិទ្ធភាពអនុវត្តការងាររបស់អាជ្ញាធរទន្លេសាប
3. ចែករំលែកគំនិតយោបល់ និងបទពិសោធន៍ការងារ ពង្រឹងប្រសិទ្ធភាពការងាររបស់អាជ្ញាធរទន្លេសាប
4. កំណត់ទិសដៅការងារសំខាន់ៗ ដើម្បីចូលរួមចំណែកដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប

**កិច្ចប្រជុំបានដំណើរការដោយមាន ៖**

- បទបង្ហាញរបស់**ឯកឧត្តម សរ គឹមសាន្ត** អគ្គលេខាធិការ អាជ្ញាធរទន្លេសាប ស្តីពី "វឌ្ឍនភាពការងារ និងទិស ដៅបន្តរបស់អាជ្ញាធរទន្លេសាប"
- បទបង្ហាញក្រុមការងារបច្ចេកទេសអាជ្ញាធរទន្លេសាប ស្តីពី "**បច្ចុប្បន្នភាពផែនទីដែនព្រៃលិចទឹកតំបន់៣**"
- ពិភាក្សា និងពិគ្រោះយោបល់រួម

បន្ទាប់ពីឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានថ្លែង សន្ទរកថាស្វាគមន៍បើកកិច្ចប្រជុំ បទបង្ហាញ និងពិនិត្យពិភាក្សារួចមក អង្គប្រជុំបានឯកភាព និងគាំទ្រ ដូចខាងក្រោម ៖

1. គាំទ្រការបោះបង្គោលកំណត់ព្រំការពារដែនព្រៃលិចទឹកតំបន់៣ តំបន់២ និងតំបន់កាត់ផ្តៀល
2. ការស្តារបឹងទន្លេសាប និងស្ទឹងទាំង ១១ ព្រមទាំងដៃស្ទឹងសំខាន់ឡើងវិញតាមទីតាំងដែលអាចស្តារបាន ដោយ រក្សាតុល្យភាពគ្នាងរវាងបឹងទន្លេសាប ជាមួយរបបទឹកទន្លេមេគង្គ
3. សិក្សាការជីកប្រឡាយការពារតំបន់៣ ជុំវិញបឹងទន្លេសាប និងធ្វើទំនប់ស្ទាក់ទឹកនៅផ្នែកខាងលើ

4. ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ពន្លឿនការចុះបញ្ជីដីតំបន់៣ ជុំវិញបឹងទន្លេសាប ចូលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ជូនអាជ្ញាធរទន្លេសាប
5. អាជ្ញាធរទន្លេសាប ធ្វើការរៀបចំផែនទីបឹងទន្លេសាប
6. អាជ្ញាធរទន្លេសាប បន្តពង្រឹងតួនាទី ភារកិច្ចរបស់ខ្លួន

ដើម្បីធ្វើឲ្យអនុវត្តការងារខាងលើ សម្រេចបានជោគជ័យ **ឯកឧត្តម រដ្ឋមន្ត្រី និងជាប្រធាន អាជ្ញាធរទន្លេសាប** បានផ្តល់មតិណែនាំ និងអនុសាសន៍ក្នុងពិធីបិទកិច្ចប្រជុំ ដូចខាងក្រោមៈ

1. ស្នើក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី បន្តផ្តល់កិច្ចសហការ ចូលរួមជាមួយក្រុមការងាររបស់អាជ្ញាធរទន្លេសាប ក្នុងការបំពេញតួនាទី ភារកិច្ច ការបោះបង្គោលព្រំកំណត់តំបន់ ៣ តំបន់២ និងតំបន់កាត់ឆ្វៀល ដូចបានកំណត់ក្នុងអនុក្រឹត្យ និង សជណ របស់រាជរដ្ឋាភិបាល និងការចុះផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋ
2. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមពន្លឿនការចុះបញ្ជីដីតំបន់៣ និងតំបន់២ ដែលនៅសល់
3. ក្រសួង ស្ថាប័នពាក់ព័ន្ធជាអ្នកអនុវត្តការងារពាក់ព័ន្ធវិស័យរបស់ខ្លួន ដែលស្នើដោយអាជ្ញាធរទន្លេសាប
4. ក្រសួងធនធានទឹក និងឧតុនិយម បានសិក្សា និងដាក់សំណើជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច លើការសាងសង់ប្រឡាយក្លិចទឹកធ្វើជាព្រំតំបន់៣ និងអាងទឹកនៅតំបន់២
5. ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពន្លឿនផ្តល់ថវិកា ដើម្បីក្រុមការងារចុះអនុវត្តការងារបោះបង្គោលបានទាប់
6. កិច្ចប្រជុំសមាសភាពអាជ្ញាធរទន្លេសាបនេះ នឹងមានរៀបចំជាបន្តបន្ទាប់ និងមានមានដំណើរទស្សនកិច្ចរួមគ្នានៅតំបន់បឹងទន្លេសាប ។

ជារួមកិច្ចប្រជុំ បានវាយតម្លៃខ្ពស់ពីសមិទ្ធផលការងារដែលអាជ្ញាធរទន្លេសាបសម្រេចបាន ក្នុងការអនុវត្តបេសកកម្ម តួនាទី ភារកិច្ច និងការអនុវត្តបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្តីពី **" ការថែរក្សា ការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងដែនព្រៃលិចទឹកក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប"** ប្រកបដោយ **ប្រសិទ្ធភាព សុក្រឹតភាព និងចីរភាព និងជាទ្រព្យសម្បត្តិមហាសាល សម្រាប់ឧត្តមប្រយោជន៍ជាតិនាពេលបច្ចុប្បន្ន និងទៅអនាគត។**

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម**ឯកឧត្តមប្រធាន** មេត្តាពិនិត្យ ជ្រាបជារបាយការណ៍ និងផ្តល់ការណែនាំបន្ថែមដ៏ខ្ពង់ខ្ពស់បំផុត ។

សូម**ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០២៤

**បានឃើញ និងសូមគោរពជូន**
ឯកឧត្តមប្រធាន មេត្តាពិនិត្យ ជ្រាបជារបាយការណ៍
និងផ្តល់ការណែនាំបន្ថែមដ៏ខ្ពង់ខ្ពស់បំផុត ។
**អនុប្រធានភ្ជាប់រួម**

**ហ៊ើល គូនី**

**អគ្គលេខាធិការ**

**សរ គឹមសាន្ត**

28/03/24

**ចម្លងជូន ៖**
-ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
-សមាជិកសមាសភាពអាជ្ញាធរទន្លេសាប
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ